**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Jan-2012, 10:34
CMS/CFO: Phok Chanthan

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ អៀង សារី សុំអនុញ្ញាតដាក់ការឆ្លើយតប**

**និង**

**ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលដកលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

---

**ដាក់ដោយ:**

**សហមេធាវី:**

អាង ឧត្តម
Michael G. KARNAVAS

**អង្គជំនុំជម្រះតុលាការកំពូល:**

**ចៅក្រម គង់ ស្រ៊ឹម**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម ម៉ុង មុនីចរិយា**

**ចៅក្រម  យ៉ា ណារិន**

**ចៅក្រម  MOTOO Noguchi**

**ចៅក្រម  Agnieszka KLONOWIECKA-MILART**

**ចៅក្រម  Chandra Nihal JAYASINGHE**

**ចៅក្រម បម្រុង ស៊ិន រិទ្ធ**

**ចៅក្រម បម្រុង Florence MUMB**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

ក្រុមមេធាវីការពារក្តីទាំងអស់

ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់

# សំណើសុំអនុញ្ញាតដាក់ការឆ្លើយតប

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) ស្នើសុំអនុញ្ញាតធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី[១] ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលដកលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (“ចម្លើយតប”)[២]។ ការឆ្លើយតបត្រូវតែធ្វើឡើងជាចាំបាច់ដោយសារការិយាល័យសហព្រះរាជអាជ្ញាមានកំហុសនៅក្នុងការអះអាងថា បណ្តឹងសាទុក្ខមិនអាចទទួលយកបានទេ ពីព្រោះសេចក្តីសម្រេចដែលរងការជំទាស់[៣] បន្តកិច្ចដំណើរការនីតិវិធី មិនមែនបញ្ចប់កិច្ចដំណើរការនីតិវិធីនោះទេ[៤]។ សេចក្តីសម្រេចដែលរងការជំទាស់ពិតជាមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ដូចនេះហើយបណ្តឹងសាទុក្ខអាចទទួលយកបានអនុលោមតាមវិធាន ១០៤។ បណ្តឹងសាទុក្ខក៏អាចទទួលយកបានផងដែរ អនុលោមតាម វិធាន ២១ នៃវិធានផ្ទៃក្នុង។ ការិយាល័យសហព្រះរាជអាជ្ញាបានបោះបង់ចោលសិទ្ធិរបស់ ខ្លួនក្នុងការដាក់ចម្លើយតបទៅនឹងអង្គសេចក្តីនៃបណ្តឹងសាទុក្ខ ដោយកម្រិតចម្លើយតបរបស់ខ្លួនត្រឹមភាព អាចទទួលយកបាន។ ដូចដែលការិយាល័យសហព្រះរាជអាជ្ញាបានឆ្លើយតបរួចហើយទៅនឹងបណ្តឹងសាទុក្ខ សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល “ធ្វើការណែនាំដល់ភាគីនានាថា កុំឲ្យដាក់ចម្លើយតបមកទៀត” គឺជាសំណើគ្មានន័យទេ។ សារណាតបនេះមិនគួរច្រានចោលនូវសវនាការដោយផ្ទាល់មាត់ ជាសាធារណៈលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខនោះឡើយ ដូចដែលមេធាវីការពារក្តីបានស្នើសុំ ពីព្រោះ ការឆ្លើយតបនេះត្រូវបានកម្រិតត្រឹមតែបញ្ហានៃភាពអាចទទួលយកបានប៉ុណ្ណោះ[៥]។

---

[១] បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងដែលដកលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E95/8/1/1 (“បណ្តឹងសាទុក្ខ”)។

[២] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលដកលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E95/8/1/2 ។

[៣] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E95/8។

[៤] ចម្លើយតប កថាខណ្ឌ ២។

[៥] សេចក្តីណែនាំអនុវត្ត ៨.៤ ចែងថា ការឆ្លើយតបទៅនឹងសារណាតប ត្រូវបានអនុញ្ញាតតែក្នុងករណីដែលមិនមានការស្នើសុំឲ្យមានការដេញដោលផ្ទាល់មាត់ប៉ុណ្ណោះ។

## ការឆ្លើយតប

១. ដោយបានអនុញ្ញាតឲ្យមានការដាក់ញត្តិរបស់ការិយាល័យសហព្រះរាជអាជ្ញា[៦] អង្គជំនុំជម្រះសាលាដំបូងបានរំលោភលើគោលការណ៍នីត្យានុកូលភាព ដោយកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានកំណត់នៅក្នុងដីកាដំណោះស្រាយដែលត្រូវបានកែប្រែដើម្បីដកចេញនូវទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ។ ពេលនេះ លោក អៀង សារី ប្រឈមមុខនឹងការកាត់សេចក្តីចំពោះឧក្រិដ្ឋកម្ម ដែលគ្មានធាតុផ្សំដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលនៃយុត្តាធិការក្នុងពេលវេលារបស់ អ.វ.ត.ក។ ដោយសារតែការភ័ន្តច្រឡំរបស់អង្គជំនុំជម្រះសាលាដំបូង ភស្តុតាងដែលពាក់ព័ន្ធទៅនឹងទំនាក់ទំនងជាមួយ នឹងជម្លោះប្រដាប់អាវុធនឹងមិនត្រូវបានបង្ហាញ នៅក្នុងពេលសវនាការលើកទីមួយនោះទេ។ មេធាវីការពារក្តីបានប្តឹងសាទុក្ខប្រឆាំងនឹងការរំលោភលើគោលការណ៍នីត្យានុកូលភាព និងបានពន្យល់ថាដោយសារតែការភ័ន្តច្រឡំរបស់អង្គជំនុំជម្រះសាលាដំបូង កិច្ចដំណើរការនីតិវិធីនឹងត្រូវបានបញ្ចប់។

២. បណ្តឹងសាទុក្ខអាចទទួលយកបាន អនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ដែលផ្តល់ដល់អង្គជំនុំជម្រះតុលាការកំពូលនូវយុត្តាធិការលើបណ្តឹងសាទុក្ខភ្លាមៗ នៅពេលដែលសេចក្តីសម្រេចដែលរងការជំទាស់មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី។ វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងត្រូវតែអនុវត្ត នៅពេលដែលសេចក្តីសម្រេចដែលរងការជំទាស់បញ្ចប់កិច្ចដំណើរការនីតិវិធី *ជាចាំបាច់* មិនមែនតែនៅពេលដែលសេចក្តីសម្រេចដែលរងការជំទាស់បញ្ចប់កិច្ចដំណើរការនីតិវិធី *ភ្លាមៗ* ប៉ុណ្ណោះទេ។

៣. សេចក្តីសម្រេចដែលរងការជំទាស់មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី នៃសវនាការលើកទីមួយនៃសំណុំរឿង ០០២ ពីព្រោះសវនាការលើកទីមួយដោះស្រាយលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតែមួយប៉ុណ្ណោះ[៧]។ ភស្តុតាងដែលពាក់ព័ន្ធទៅនឹងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស

---

[៦] សំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E95។

[៧] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E124 កថាខណ្ឌ ៥។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E124/7។

ជាតិ - ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ - នឹងមិនត្រូវបានបង្ហាញនៅក្នុងអំឡុងពេលសវនាការលើកទីមួយនោះទេ ដោយសារតែសេចក្តីសម្រេចដែលរងការជំទាស់ ដែលបានរកឃើញថា គ្មានលក្ខខណ្ឌកំណត់ស្តីពីចំណងទាក់ទងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ឡើយ។ ជាយថាហេតុ ទោះបីជាមិនមែននៅពេលនេះក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលក៏ *នឹង*ត្រូវបើកការសួរដេញដោលលើបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ពីព្រោះអង្គជំនុំជម្រះសាលាដំបូង មានការភ័ន្តច្រឡំលើបញ្ហាអង្គច្បាប់ដែលបានទុកជាមោឃៈនូវសេចក្តីសម្រេចដែលរងការជំទាស់[៨]។ សម្រាប់សំអាងហេតុនានាដែលបានកំណត់នៅក្នុងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលអាច និងគួរតែសម្រេចថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ពិតជាតម្រូវឲ្យមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ។ ដោយសារតែភស្តុតាងដែលពាក់ព័ន្ធនឹងទំនាក់ទំនងនេះនឹងមិនត្រូវបានបង្ហាញទេនោះ ពុំមានជនជាប់ចោទណាម្នាក់នឹងត្រូវបានផ្តន្ទាទោសអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ នៅទីបំផុត។ ធាតុផ្សំចាំបាច់នៃឧក្រិដ្ឋកម្មនេះនឹងមិនត្រូវបានបង្ហាញភស្តុតាងឡើយ។ ដូចនេះ កិច្ចដំណើរការនីតិវិធីនឹងបញ្ចប់ជាចាំបាច់ ដែលជាលទ្ធផលផ្ទាល់នៃសេចក្តីសម្រេចដែលរងការជំទាស់។ ដូចនេះ ការិយាល័យសហព្រះរាជអាជ្ញាមានកំហុសដោយអះអាងថា ពុំមានមូលដ្ឋាន គតិយុត្តិណាមួយដើម្បីគាំទ្រដល់បណ្តឹងសាទុក្ខភ្លាមៗស្របតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ឡើយ និងថាសេចក្តីសម្រេចដែលរងការជំទាស់បន្តកិច្ចដំណើរការនីតិវិធីទៅមុខទៀត ជាជាងបញ្ចប់កិច្ចដំណើរការនីតិវិធី[៩]។

៤. វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង មិនត្រូវបានកម្រិតត្រឹមសេចក្តីសម្រេចដែលរងការជំទាស់ដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី *ភ្លាមៗ* នោះទេ។ មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល ធ្វើតាមគោលការណ៍ណែនាំរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា (“ICTR”) ដែលប្រឈមនឹងបញ្ហាស្រដៀងគ្នាខ្លះៗ នៅក្នុងរឿងក្តី *Théoneste Bagosora* និង២៨នាក់ផ្សេងទៀត។ នៅក្នុងរឿងក្តីនោះ រដ្ឋអាជ្ញាបានប្តឹង

[៨] សូមមើលផងដែរ វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ដែលចែងថា អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការសម្រេច លើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ដែលនាំអោយមោឃៈសេចក្តីសម្រេចនោះ។

[៩] ចម្លើយតប កថាខណ្ឌ ២, ៤។

ឧទ្ធរណ៍លើសេចក្តីសម្រេច ដែលបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង *Théoneste Bagosora* និង២៨នាក់ផ្សេងទៀត។ វាមិនច្បាស់លាស់ទេថា តើ មាត្រា ២៤ នៃច្បាប់លក្ខន្តិកៈ ICTR ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ នឹងអនុញ្ញាតឲ្យមានបណ្តឹងឧទ្ធរណ៍បែបនេះ ដែរ ឬយ៉ាងណា[១០]។ នៅក្នុងការបកស្រាយមាត្រា ២៤ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានយល់ឃើញថា៖

> ការអានមាត្រា ២៤ នេះ ដែលនឹងផ្តល់ឲ្យរដ្ឋអាជ្ញានូវសិទ្ធិដែលមិនត្រូវបានហាមឃាត់នៃការធ្វើបណ្តឹងឧទ្ធរណ៍ ខណៈពេលដែលសិទ្ធិដែលមិនត្រូវបានហាមឃាត់នៃការធ្វើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទត្រូវបានកម្រិត នឹងរំលោភលើគោលការណ៍នៃសមភាពតទល់ក្នុងរឿងក្តី។ ជាការពិត គោលការណ៍នៃសមភាពតទល់ក្នុងរឿងក្តីតម្រូវឲ្យភាគីនានា រីករាយឆ្លើយតបនឹងសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ...។ ស្របជាមួយនឹងគោលការណ៍នេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍យល់ឃើញថា នៅក្នុងរឿងក្តីបច្ចុប្បន្ន១នេះ នៅពេលដែលបញ្ហា បានប៉ះពាល់ សិទ្ធិរបស់ជនជាប់ចោទ រដ្ឋអាជ្ញាពុំមានអំណាចធ្វើបណ្តឹងឧទ្ធរណ៍ធំជាងជនជាប់ចោទឡើយ[១១]។

ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលគួរតែបកស្រាយវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការគោរពគោលការណ៍នៃសមភាពតទល់ក្នុងរឿងក្តី។ ម្យ៉ាងវិញទៀត វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង មិនគួរយល់ឃើញថាត្រូវបានកម្រិតត្រឹមសេចក្តីសម្រេចនានាដែល

---

[១០] មាត្រា ២៤ នៃច្បាប់លក្ខន្តិកៈ ICTR ចែងថា៖

មាត្រា ២៤: កិច្ចដំណើរការនីតិវិធីប្តឹងឧទ្ធរណ៍

១. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នឹងសម្រេចលើបណ្តឹងសាទុក្ខនានាដែលធ្វើឡើងដោយជនណាដែលត្រូវបានផ្តន្ទាទោសដោយអង្គជំនុំជម្រះសាលាដំបូង ឬដោយរដ្ឋអាជ្ញាដោយផ្អែកលើមូលដ្ឋាននានាដូចខាងក្រោម:

(ក) កំហុសលើអង្គច្បាប់ដែលនាំឲ្យមោឃៈសេចក្តីសម្រេចនោះ។ ឬ

(ខ) កំហុសលើអង្គហេតុដែលបណ្តាលឲ្យមានការខកខានមិនទទួលបាននូវយុត្តិធម៌។

២. អង្គជំនុំជម្រះសាលាឧទ្ធរណ៍អាចអះអាង បដិសេធ ឬកែប្រែសេចក្តីសម្រេចទាំងឡាយដែលធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង។

[១១] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Bagosora *et al.*, ICTR-98-37-A សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាដែលកើតចេញមកពីសេចក្តីសម្រេចរបស់ចៅក្រមដែលបានបញ្ជាក់អះអាងម្នាក់ដែលបានបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំង Theonéste Bagosora នឹង ២៨នាក់ផ្សេងទៀត ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៣៤ ដល់ ៣៥។

មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី *ភ្លាមៗ* ឡើយ ពីព្រោះសេចក្តីសម្រេចទាំងនេះនឹងគ្រាន់តែត្រូវបានប្តឹងសាទុក្ខដោយការិយាល័យសហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ វានឹងមិនសមហេតុផលទេចំពោះការអះអាងថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចលើបញ្ហាដោយត្រឹមត្រូវ ការិយាល័យសហព្រះរាជអាជ្ញាអាចប្តឹងសាទុក្ខភ្លាមៗបាន ប៉ុន្តែប្រសិនបើអង្គជំនុំជម្រះសម្រេចលើបញ្ហាដោយមិនត្រឹមត្រូវ មេធាវីការពារក្តីត្រូវតែរង់ចាំស្វែងរកដំណោះស្រាយរហូតដល់ក្រោយពេលចេញសាលក្រម។ ចំណុចនេះនឹងចាត់ទុកជាការធ្វើឱ្យខូចភាពយុត្តិធម៌ និងបណ្តាលឱ្យមានភាពមិនយុត្តិធម៌។

៥. គោលការណ៍តាមរដ្ឋធម្មនុញ្ញនៃ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* (*in dubio pro reo*) និងវិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវឱ្យធ្វើការបកស្រាយវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង តាមមធ្យោបាយពាក់ព័ន្ធនឹងការការពារផលប្រយោជន៍របស់លោក អៀង សារី និងធានាអំពីសច្ចភាពគតិយុត្តិ[១២]។ ពុំមានភាពចាំបាច់ត្រូវរង់ចាំរហូតដល់ចេញសាលក្រមនោះទេ នៅមុនពេលសម្រេចថា តើអ្វីខ្លះជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ បណ្តឹងសាទុក្ខ មានការពាក់ព័ន្ធទៅនឹងបញ្ហានៃអង្គច្បាប់សុទ្ធសាធ ដែលគួរតែត្រូវបានសម្រេចភ្លាមៗដើម្បីការពារសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌របស់លោក អៀង សារី ដែលត្រូវទទួលបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើគាត់[១៣]។ លោក អៀង សារី មិនត្រូវទទួលបាននូវការបង្ខិតបង្ខំឱ្យទទួលការជំនុំជម្រះក្តីដែលមានរយៈពេលវែងនោះទេ នៅពេលដែលមានបញ្ហាជាសត្យានុម័តទាក់ទិននឹងធាតុផ្សំ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយបញ្ហាជាសត្យានុម័តនេះប៉ះពាល់ដល់ការទាញយកនូវភស្តុតាង។

៦. ការិយាល័យសហព្រះរាជអាជ្ញាចាត់ទុកដោយភ័ន្តច្រឡំថា បណ្តឹងសាទុក្ខនេះដូចគ្នានឹងបណ្តឹងសាទុក្ខមុនៗមួយចំនួនដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូល ដោយផ្អែកលើ

---

[១២] មាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញចែងត្រង់ផ្នែកពាក់ព័ន្ធថា៖ "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* (*in dubio pro reo*) អនុវត្តចំពោះសំអាងហេតុនៃអង្គច្បាប់ ដែលស្ថិតក្រោមវិធាននៃការបកស្រាយច្បាប់រដ្ឋប្បវេណី។ សូមមើល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

[១៣] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(ក)។

មូលដ្ឋាននៃភាពអាចទទួលយកបាន[១៤]។ ខុសពីបណ្តឹងសាទុក្ខចំនួនបីដែលបានយោងដោយ ការិយាល័យសហព្រះរាជអាជ្ញា បណ្តឹងសាទុក្ខពេលនេះបានផ្អែកលើវិធាន ១០៤(៤)(ក) នៃវិធាន ផ្ទៃក្នុង។ បណ្តឹងសាទុក្ខក៏អាចទទួលយកបានផងដែរផ្អែកតាមវិធាន ២១ នៃវិធានផ្ទៃក្នុងតែមួយ ពីព្រោះសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌របស់ លោក អៀង សារី នឹងត្រូវបានរំលោភបំពាន ប្រសិនបើសេចក្តីសម្រេចមិនត្រូវបានធ្វើឡើងនៅពេលនេះទេ[១៥]។ នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ដោយផ្អែកលើវិធាន ២១ នៃវិធានផ្ទៃក្នុងតែមួយនាពេលកន្លងទៅ អង្គជំនុំជម្រះតុលាការកំពូល បានធ្វើដូច្នេះដោយផ្អែកលើសេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខតែម្យ៉ាងប៉ុណ្ណោះ[១៦]។ សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខមិនបានលើកឡើងអំពីទឡ្ហីករណ៍លើអង្គសេចក្តីនោះទេ។ សេចក្តីជូនដំណឹងមានគោលបំណងគ្រាន់តែធ្វើការជូនព័ត៌មានដល់អង្គជំនុំជម្រះតុលាការកំពូល និងភាគីនានា អំពីចេតនាក្នុងការដាក់បណ្តឹងសាទុក្ខប៉ុណ្ណោះ។

ហេតុដូច្នេះ មេធាវីការពារក្តីស្នើដោយក្តីគោរពសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

ក. **យល់ឃើញ** និង**ប្រកាស**ថា បណ្តឹងសាទុក្ខពេលនេះអាចទទួលយកបាន។

ខ. **អនុញ្ញាត**ឲ្យមានសវនាការផ្ទាល់មាត់ និងជាសាធារណៈ ដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនេះ។ និង

គ. **ទុកជាមោឃៈ**នូវសេចក្តីសម្រេចដែលរងការជំទាស់ ដែលបានដកលក្ខខណ្ឌតម្រូវឲ្យមាន

---

[១៤] ចម្លើយតប កថាខណ្ឌ ៥។

[១៥] អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើវិធាន ២១ នៃវិធានផ្ទៃក្នុង កាលពី ពេលកន្លងទៅ។ *សូមមើល រឿងក្តី អៀង សារី* ០០២/១៩/០៩/២០០៧-អវតក/កសចស (អបជ ៦៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួប ជាមួយ លោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12, ERN: 00531173-00531191 កថាខណ្ឌ ១៨៖ "ក្រោយពីបានពិចារណាលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ... អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ២១ តម្រូវឲ្យខ្លួនបកស្រាយវិធានផ្ទៃក្នុង តាមមធ្យោបាយដែលមានន័យថា បណ្តឹងឧទ្ធរណ៍នេះក៏អាចទទួលយកបានតាមមូលដ្ឋាននៃវិធាន ២១ ផងដែរ"។

[១៦] សេចក្តីសម្រេចលើសេចក្តីជូនដំណឹងពីរនៃបណ្តឹងសាទុក្ខដែលដាក់ដោយ អៀង សារី ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E9/7/1/1/1/4។

ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធចេញពីនិយមន័យ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវអនុវត្តនៅក្នុងសំណុំរឿង ០០២។

សូមដាក់ជូនដោយក្តីគោរព

| អាង ឧត្តម | Michael G. KARNAVAS |
|---|---|

សហមេធាវីការពារក្តី លោក អៀង សារី

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១